# នំប្រើប្រាស់ក្នុងពិធី

នៅក្នុងសង្គមខ្មែរ មានប្រភេទនំខ្លះគេធ្វើសម្រាប់លក់ និងធ្វើសម្រាប់ហូបភ្លាមៗ។ ប៉ុន្តែក៏មាននំខ្លះទៀតគេផលិតឡើងក្នុងកិច្ចពិធីធំដុំរបស់ខ្មែរ ជាក់ស្តែងដូចជា នំជាល ដែលជានំអាចទុកបានយូរមិនងាយខូច គេច្រើនធ្វើនៅរដូវបុណ្យភ្ជុំ។ ដោយឡែក នៅតំបន់សំបូរព្រៃគុក ខេត្តកំពង់ធំ មាននំចំនួនពីរប្រភេទ ដែលគេនិយមធ្វើឡើងប្រើប្រាស់ក្នុងកិច្ចពិធីឡើងអ្នកតា និងច្រត់ព្រះនង្គ័លជាដើម ដែលនំទាំងពីរនោះមានឈ្មោះថា "នំនាលិ" និង "នំអន្សមស្ទឹកផ្អាវ"។

នាលិ សំដៅដល់ឧបករណ៍ពុម្ពសម្រាប់ធ្វើនំ ហើយពុម្ពនោះ គឺជាត្រឡោកដែលគេចោះរន្ធមួយចំនួននៅគូទសម្រាប់ចំហុយម្សៅអង្ករ។[១] អ្នកស្រុកនៅតំបន់នោះច្រើនធ្វើនំនាលិប្រើប្រាស់ក្នុងកិច្ចពិធីឡើងអ្នកតា និងពិធីច្រត់ព្រះនង្គ័លដែលជាពិធីបុណ្យទៀងទាត់ដ៏សំខាន់នៅក្នុងភូមិ ជាក់ស្តែងដូចឃើញមាននៅភូមិសំបូរ និងភូមិចំណារចាស់ (រូបលេខ១-៣)។ នៅមុនពេលពិធីឡើងអ្នកតាមួយថ្ងៃ អ្នកភូមិសំបូរស្ទើរគ្រប់ផ្ទះតែងតែធ្វើនំនាលិយកទៅចូលបុណ្យនឹងគេ នៅពេលគេដើររៃអង្គាស។ ក្នុងថ្ងៃឡើងអ្នកតា ដែលប្រារព្ធនៅកណ្ដាលភូមិ (អ្នកតាទ្វារ) និងនៅខ្ទមអ្នកតាមុខក្រុមប្រាសាទសំបូរ គេយកនំនាលិធ្វើជាសំណែនដល់អ្នកតា (រូបលេខ៤-៦)។ ប៉ុន្តែ នៅមុនពេលកិច្ចបំពេញឃ្វាំង គេបានចែកនំនាលិដល់អ្នកស្រុកដែលបានមកចូលរួម ហើយការចែកនំនៅពេលនោះគេហៅថា "ចែកល្បែ" ពោល គឺជាការចែកទានពីអ្នកតាជូនដល់កូនចៅ ដែលពាំនាំមកនូវភាពសុខសប្បាយ (រូបលេខ៧)។

ចំណែកនៅក្នុងពិធីច្រត់ព្រះនង្គ័លវិញ គេចាត់ទុកនំនាលិតំណាងឲ្យដីរបស់អ្នកស្រុក។ ដ្បិត អ្នកស្រុកដែលទៅចូលរួមពិធីនេះ បានយកក្ដួរស្រូវដែលធ្វើអំពីលាជចងភ្ជាប់ជាមួយធូបនិងអំបោះក្រហម មកដោតនៅលើនំនាលិ ដោយខ្លះមានហ៊ុំព័ទ្ធដោយក្រណាត់ជុំវិញមកដាក់សែននៅក្នុងខ្ទមអ្នកតា (រូបលេខ៨-១១)។ ប៉ុន្តែពេលចប់កិច្ចគេយកនំនាលិទៅវិញ។ នំនាលិ ក៏មិនសូវខុសពីនំជាលដែរ គឺគេអាចរក្សាទុកហូបបានយូរដូចគ្នា។ យើងពុំដឹងថាប្រពៃណីនៃការធ្វើនំនេះមានពីពេលណាមកទេ តែប្រហែលមានជាយូរមកហើយ ពោល អាចដំណាលគ្នានៃការកកើតពិធីនេះក៏ថាបាន។

ដោយឡែក សម្រាប់នំអន្សមស្ទឹកផ្អាវ ឬនំស្បង់វិញ យើងឃើញគេតែងប្រើប្រាស់នៅក្នុងកិច្ចពិធីឡើងអ្នកតាក្នុងភូមិចុងព្រៃ និងភូមិព្រៃព្រះ (រូបលេខ១២-១៤)។ នៅក្នុងកិច្ចនោះ យើងពុំឃើញ

---

[១] អាំង ជូលាន, នំនាលិ, *ផ្សាយក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ* http://www.yosothor.org/publications/khmer-renaissance/chapter-one/num-nal.html ។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

មានទំនាលិដូចកិច្ចពិធីនៅភូមិសំបូរ និងភូមិចំណារចាស់ឡើយ តែគេជំនួសវិញដោយនំអន្សមស្លឹកផ្អាវៗ មើលតាមគំនិតនៃកិច្ចឡើងអ្នកតា នំនេះពុំខុសពីនំនាលិឡើយ គឺអ្នកស្រុកតែងតែធ្វើនំអន្សមស្លឹកផ្អាវយកមកចូលបុណ្យឡើងអ្នកតា ដែលក្នុងកិច្ចនោះគេដាក់សែននំនេះយ៉ាងច្រើននៅមុខខ្ទមអ្នកតា។ ក្នុងកិច្ចបញ្ជូនរូបស្នងអ្នកតាដែលតែងតែជិះលើដំរី (ដំរីជាកូនចៅ) បានយកនំស្បង់ឬនំអន្សមស្លឹកផ្អាវដាក់លើខ្នង ហើយនៅពេលទៅដល់រូបស្នងបានយកនំស្បង់បាចចូលទៅក្នុងព្រៃក្នុងន័យសូមឱ្យគ្រោះចង្រៃដែលមាននៅក្នុងភូមិចៀសចេញឱ្យផុត (រូបលេខ១៥-១៦)។ បន្ទាប់មកទៀត នៅមុនបញ្ចប់នៃកិច្ចរូបស្នងអ្នកតាបានចែកនំនេះជូនដល់កូនចៅដែលមកចូលរួម ក្នុងន័យសូមឱ្យសុខសប្បាយ វៀរចាកពីជំងឺដង្កាត់ទាំងពួង។



រូបលេខ១៖ នំនាលិ





រូបលេខ២-៣៖ ការផលិតនំនាលិ

អត្ថបទដោយ៖ ម៉ង់ វ៉ាលី





រូបលេខ៤-៥៖ ការរែអង្គាសនំនាលិមុនមួយថ្ងៃនៃកិច្ចឡើងអ្នកតានៅភូមិសំបូរ





រូបលេខ៦-៧៖ សំណៃននំនាលិក្នុងកិច្ចឡើងអ្នកតា និងការចែកល្បែនំនាលិពីលោកតាមកកូនចៅ





រូបលេខ៨-៩៖ នំនាលិប្រើប្រាស់ក្នុងពិធីច្រត់ព្រះនង្គ័លនៅភូមិសំបូរ




រូបលេខ១០-១១៖ នំនាលិក្នុងពិធីច្រត់ព្រះនង្គ័លនៅភូមិសំបូរ និងភូមិចំណារចាស់




រូបលេខ១២-១៣៖ នំអន្សមស្ទឹកផ្អាវ ឬនំស្បង់ ប្រើប្រាស់ក្នុងពិធីឡើងអ្នកតាភូមិចុងព្រៃ



រូបលេខ១៤៖ នំអន្សមស្ទឹកផ្អាវ ឬនំស្បង់
ប្រើប្រាស់ក្នុងពិធីឡើងអ្នកតាភូមិចុងព្រៃ



រូបលេខ១៥៖ ការប្រើប្រាស់នំស្បង់ក្នុងកិច្ច
បញ្ជូននៃពិធីឡើងអ្នកតាភូមិចុងព្រៃ

អត្ថបទដោយ៖ ម៉ង់ រ៉ាលី

## ឯកសារយោង

អាំង ជូលាន

*នំនាលិ, បណ្ដាញព័ត៌មានវប្បធម៌ខ្មែរ,*

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

http://www.yosothor.org/publications/khmer-renaissance/chapter-one/num-nal.html

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ ម៉ង់ រ៉ាលី